# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**


លេខ: ……… ស.ខ.ក.ក.

## សេចក្តីអំពាវនាវ

កាលពីថ្ងៃទី០៨ និង ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤នេះ ស្ថានទូតវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា លោក Tran Van Thong អ្នកនាំពាក្យស្ថានទូតវៀតណាម ប្រចាំកម្ពុជា ហើយនិងលោក Lê Hải Bình អ្នកនាំពាក្យក្រសួងការបរទេសវៀតណាម បានចេញសេចក្តីថ្លែងការណ៍ និងថ្លែងបញ្ជាក់ របៀបផ្តើន និងមើលងាយប្រជារាស្ត្រខ្មែរម្តងហើយម្តងទៀត ដោយហៅក្រុមបាតុករខ្មែរថា ជាក្រុមមួយក្តាប់តូច។ មានន័យថា ប្រជារាស្ត្រខ្មែរ ដែលមិនបានចូលរួមធ្វើបាតុកម្ម គាំទ្រឲ្យយួនបំភ្លៃប្រវត្តិសាស្ត្រខ្មែរតាមអំពើចិត្តឬ?

ដើម្បីសម្តែងនូវសាមគ្គីភាពឈាមខ្មែរតែមួយ សហគមន៍ខ្មែរកម្ពុជាក្រោម សូមអំពាវនាវព្រះករុណាគ្រប់ព្រះអង្គ បងប្អូនរួមឈាមទាំងអស់ ព្រះមេត្តា និងមេត្តា និមន្តនិងអញ្ជើញចូលរួមធ្វើមហាបាតុកម្មជាមួយសហគមន៍ខ្មែរកម្ពុជាក្រោម និងសម្ពន្ធយុវជនខ្មែរឯករាជ្យ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០១៤ កុំបីខាន និងសូមអំពាវនាវដល់បងប្អូនរួមឈាមខ្មែរនៅឯនាយសមុទ្រទាំងអស់ រៀបចំធ្វើបាតុកម្មឲ្យបានគ្រប់ប្រទេស ដែលមានប្រជារាស្ត្រខ្មែររស់នៅ ដើម្បីបង្ហាញពីសាមគ្គីជាតិ និងប្រាប់ទៅរដ្ឋាភិបាលយួនថា ប្រជារាស្ត្រខ្មែរមិនអាចទទួលយកការប្រមាថមើលងាយរបស់រដ្ឋាភិបាលយួនបានទេ និងប្តេជ្ញាការពារប្រវត្តិសាស្ត្រខ្មែរឲ្យបានជាដាច់ខាត។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម

**ថាច់ សេដ្ឋា**

អតីតសមាជិកព្រឹទ្ធសភា

---


ទីស្នាក់ការ: ផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី
ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា; ទូរស័ព្ទលេខ: (៨៥៥) ៧៨ ៨៩៨ ៨៨២ / ៩៣ ៤៧ ៤៧ ០៦
អាសយដ្ឋានអ៊ីមែល: thachsetha13@gmail.com, kkcpressoffice@yahoo.com
Website: khmerkromngo.org; Facebook: khmerkkcommunity